ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ

## រយៈពេល ៣ ឆ្នាំ

## (២០០៨-២០១០)

ឈ្មោះសហគមន៍នេសាទ : កំពង់ខ្លាញ់

ភូមិ : កំពង់ខ្លាញ់

ឃុំ : ជលសា

ស្រុក : ជលគិរី

ខេត្ត : កំពង់ឆ្នាំង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ
# រយៈពេល ៣ ឆ្នាំ
# (២០០៨-២០១០)

ឈ្មោះសហគមន៍នេសាទ : កំពង់ខ្លាញ់
ភូមិ : កំពង់ខ្លាញ់
ឃុំ : ជលសា
ស្រុក : ជលគីរី
ខេត្ត : កំពង់ឆ្នាំង

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទ ឫស្សីដង្កូចត្រូវបានបង្កើតឡើង ដោយមហាសន្និបាតកំណើតដំបូងនៅថ្ងៃទី **២២** ខែ **មិថុនា** ឆ្នាំ **២០០៧** និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី **១១** ខែ **មករា** ឆ្នាំ **២០០៨**។

សហគមន៍នេសាទ **កំពង់ខ្នាញ់** មានទីតាំងស្ថិតនៅក្នុងភូមិ **កំពង់ខ្នាញ់** ឃុំ **ជលសារ** ស្រុក **ជលគីរី** ខេត្ត **កំពង់ឆ្នាំង** ដែលមានសមាជិកសរុបចំនួន **១២០** នាក់ ស្រីចំនួន **៦២** នាក់ និងមានគណៈកម្មការចំនួន **៧** នាក់ ស្រីចំនួន **គ្មាន**។ ក្នុងនោះចំនួនគ្រួសារសរុបមានចំនួន **៧០** គ្រួសារ ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមាន:

- ចុះបង្ក្រាបបទល្មើសនេសាទស្បៃមុង
  - ចុះធ្វើការទប់ស្កាត់ការកាប់ព្រៃលិចទឹក
  - ចុះល្បាត
  - បោះបង្គោល
  - ដាក់លូ
  - ស្តារប្រឡាយ

## អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក -ប្រជាជនសរុប:

- ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទមាន **៤៨៩** នាក់ ប្រុស **២៥០** នាក់ ស្រី **២៣៩** នាក់ **៨២** គ្រួសារក្នុងនោះមានជនជាតិខ្មែរចំនួន **គ្មាន** ខ្មែរឥស្លាមចំនួន **គ្មាន** អាណិកជនវៀតណាមចំនួន **គ្មាន**។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ១២ នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ១ នាក់ ស្រី គ្មាន
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ៣ នាក់ ស្រី ២ នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន ៤ នាក់ ស្រី ១ នាក់
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន ៥ នាក់ ស្រី ២ នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ **១០០%**។ ក្រៅពីនេះមានអ្នកកាន់សាសនា អ៊ិស្លាម ប្រមាណ **គ្មាន** សាសនាកាតូលិកប្រមាណ **គ្មាន**។

- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន **៩៥** នាក់ ស្រី **៤៨** នាក់ កំរិតថ្នាក់បឋមសិក្សាចំនួន **៦២** នាក់ ស្រី **១៤** នាក់ កំរិតមធ្យមសិក្សា ចំនួន **៣** នាក់ ស្រី **គ្មាន** និងកំរិតថ្នាក់ឧត្តមសិក្សាចំនួន **គ្មាន** ស្រី **គ្មាន**

**ខ-មុខរបរ**

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមានៈ

- ធ្វើនេសាទចំនួន ៨២ គ្រួសារ
- ធ្វើស្រែចំនួន ៨២ គ្រួសារ ទំហំ ២៥០ ហិកតា ( ប្រាំង)
- ដាំបន្លែចំនួន ២៥ គ្រួសារ ទំហំ ០,៥ ហិកតា
- ជាងផ្ទះចំនួន ៤ គ្រួសារ
- ធ្វើចំការចំនួន ៥៥ គ្រួសារ ទំហំ ២៨ ហិកតា
- លក់ដូរចំនួន ៧ គ្រួសារ ( លក់ចាប់ហួយ)
- កែច្នៃផលនេសាទ ៦១ គ្រួសារ
- ធ្វើសិប្បកម្ម ៣ គ្រួសារ ( ត្បាញកន្ទេលកក់

**៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍**

**ក. ទីតាំង**

កន្លែងនេសាទសហគមន៍ **កំពង់ខ្លាញ់** ជាកន្លែងដែលត្រូវបានកាត់ចេញពីឡូត៍នេសាទលេខ **១៥** និងដែននេសាទទឹកសាប ។

កន្លែងនេសាទសហគមន៍ **កំពង់ខ្លាញ់** មានទំហំ **៦៧៥** ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ។

មានព្រំប្រទល់ :

- ខាងជើងទល់នឹង **ជីតាសុខ.**
- ខាងត្បូងទល់នឹង **គរជ្រុំ**
- ខាងកើតទល់នឹង **ឬស្សីដង្កូច**
- ខាងលិចទល់នឹង **ទន្លេ**

**ខ. ដែននេសាទ**

កន្លែងនេសាទសហគមន៍ **កំពង់ខ្លាញ់** មានបឹងចំនួន **៣** ព្រែកចំនួន **២** ប្រឡាយចំនួន**១** ត្រពាំងចំនួន **គ្មាន** បៀចំនួន **គ្មាន** និងមេទឹកចំនួន **គ្មាន** ។

- បឹងឈ្មោះ **បឹងផ្តៅ.** ទំហំ ៨០០០០ម$^{២}$ នៅសាទពីខែ ពេញ ១ឆ្នាំ
- បឹងឈ្មោះ **ឫស្សីដង្គួច** ទំហំ ១៥០០០ម$^{២}$ នៅសាទពីខែ ពេញ ១ឆ្នាំ
- បឹងឈ្មោះ **បឹងអញ្ចាញ** ទំហំ ៨០០០០ម$^{២}$ នៅសាទពីខែ ពេញ ១ឆ្នាំ
- បឹងឈ្មោះ **បឹងពាមជ្រៅ** ទំហំ នៅសាទពីខែ កញ្ញាដល់ខែ ធ្នូ
- បឹងឈ្មោះ **បឹងផ្តៅ** ទំហំ ៨០០០០ម$^{២}$ នៅសាទពីខែ កញ្ញា ដល់ខែ ធ្នូ
- ទំនាបលិចទឹកឈ្មោះ **តាប៉ាង** ទំហំ ២០០០០ម$^{២}$ នៅសាទពីខែ កញ្ញា ដល់ខែ ធ្នូ
- ទំនាបលិចទឹកឈ្មោះ **តាហេង** ទំហំ ៤៥០០ម$^{២}$ នៅសាទពីខែ កញ្ញា ដល់ខែ ធ្នូ
- ព្រៃលិចទឹកតំបន់បឹងអញ្ចាញមានទំហំសរុប **២** ហិកតា ។

**គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

- បឹងឈ្មោះ **បឹងអញ្ចាញ** ទំហំ **៨** ហិកតា ( បណ្តោយ ៨០០ម ទទឹង ៥០ម x ២ )
- ព្រៃឈ្មោះ **បឹងអញ្ចាញ** ទំហំ ២ ហិកតា

**ឃ. ធនធានផលផល**

**ឃ.១ <u>ប្រភេទត្រី</u> :**

ឃ.១.១ ប្រភេទត្រីកើនឡើង

ត្រីខ្នាន់, រៀល,លិញ,ក្បាលឡាន,ប្រម៉ា, រស់,ស្លាត,ឆ្ពោរ, កញ្ជ្រូក ។

ឃ.១.២ ប្រភេទត្រីថយចុះ

គាតស្រង់,ឆ្លាំង,កញ្ចុះ, អណ្តែង,ក្រមំម,ឆ្កោក,ក្លាំងហាយ, ឆ្ពិន,ច្រកែង,ឆ្ពិន,អំពិលទុំ,ព្រលូង, ។

ឃ.១.៣ ប្រភេទត្រីដដែល

គ្មាន

**ឃ.២ <u>ប្រភេទវារីសត្វ</u>**

ឃ.២.១ ប្រភេទវារីសត្វកើន

កំពីស,ខ្យង,ប្រវឹក,ទុង,ក្អែកទឹក,អែអូត,សារិកាកែវ,លលក,ចាប,កុក,ត្រយ៉ង,កាហ៊ិត ។

ឃ.២.២ ប្រភេទវារីសត្វថយចុះ

អណ្តើក,កន្ធាយ,ពស់,ក្តាម,ក្រសា,មៀម,ទាព្រៃ ។

ឃ.២.៣ ប្រភេទវារីសត្វដដែល

គ្មាន

**ឃ.៣ <u>ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ</u>**

ឃ.៣.១ ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិកើន

រាំង,ត្រស់,អាញ្ញា,កំប្លោក,រំពាក់ទឹក,ចំផ្លង,កន្ទ្រាំងហៃ,ស្នោរ,វល្លិ៍ដូងព្រះ,វល្លិប្រេង។

ឃ.៣.២ ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិថយចុះ

បបួយ,អញ្ចាញ,ត្រគួន,ទៀនព្រៃ។

ឃ.៣.៣ ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិនៅដដែល

គ្មាន

## ៤. ការធ្វើនេសាទ

### ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន **១៧៩** នាក់ ស្រី **៦៥** នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍មានចំនួន **១៥** នាក់ ស្រី **៧** នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន **១០០** នាក់ ស្រី **៤០** នាក់

### ខ. ឧបករណ៍នេសាទ

- ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ:

| **ប្រភេទ ឧបករណ៍** | **ឯកតា** | **ចំនួនសរុប** | **បរិមាណផល សរុប គ.ក្រ** | រដូវប្រើប្រាស់ឧបករណ៍ (ខែ......ដល់ ខែ........) |
|---|---|---|---|---|
| មង | នាក់/ដៃ/គក្រ/ថ្ងៃ | ៧២ x ៤ x ២ x ៦០ | ៣៤៥៦០ | ០៨-១០ |
| បង្កៃ | នាក់/ផ្លែ/គក្រ/ថ្ងៃ | ១០ x ១០០ x ១ x ១៥០ | ១៥០០០០ | ១២-០៤ |
| សន្ទូចរនង | នាក់/ផ្លែ/គក្រ/ថ្ងៃ | ១១០ x ២០០ x ៣ x៣០ | ១៩៨០០០០ | ១០-១១ |
| លប | នាក់/គ្រ/គក្រ/ថ្ងៃ | ២០ x ២០ x ១ x ៣០ | ១២០០០ | ១២-០៥ |
| ឡើ | នាក់/គ្រ/គក្រ/ថ្ងៃ | ១០ x ១០០ x ១ x ៥០ | ៥០០០០ | ០៩-១២ |
| អង្រុត | នាក់/គ្រ/គក្រ/ថ្ងៃ | ៣០ x ១ x ២ x ១៨០ | ១០៨០០ | ០៥-០៧ |

| **ប្រភេទទូក កាណូត** | **ចំនួន** (គ្រឿង) | **ចំណុះ** (គ.ក្រ) | **កំលាំងសេះ** |
|---|---|---|---|
| ទូកត្នោត | ២ | ១០០ | |
| ទូកឈើ | ១១៣ | ៥០០-១០០០ | ៣-១៥ សេះ |
| ទូកឈើ | ៣០ | ២០០ | គ្មាន |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទៈ

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួនសរុប | បរិមាណផល សរុប គ.ក្រ |
|---|---|---|---|
| មង | នាក់ | ៦ | ៥០០គក្រ |
| បង្កៃ | នាក់ | ៣ | ៣០០គក្រ |
| សន្ទូចរនង | នាក់ | ២ | ១៥០គក្រ |
| លប | នាក់ | ១ | ១៨០គក្រ |
| អង្រុត | នាក់ | ២ | ១៣០គក្រ |

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកឈើ | ៧០ | ៥០០-១០០០ | ៣-១៥ សេះ |
| ទូកឈើ | ១៨ | ២០០ | គ្មាន |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទៈ

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួនសរុប | បរិមាណផល សរុប (គ.ក្រ) |
|---|---|---|---|
| មង | នាក់ | ៣០ | |
| បង្កៃ | នាក់ | ៥០ | |
| សន្ទូចរនង | នាក់ | ១០ | |
| អង្រុត | នាក់ | ១៥ | |
| សំណាញ់ | នាក់/គក្រ/ថ្ងៃ | ១៥ x ១ x ៤ x ៨០ | ៤ ៨០០ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| **អ្នកទាំងនោះមកធ្វើនេសាទនៅរដូវប្រាំងដោយថ្មើរ ជើងនិងកង់** | | | |

គ. ចំនួនប្រមាណ ផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ *(គិតជា គក)* | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៣៥០០ គក្រ | ៣២០០ គក្រ | ៦៥០០ គក្រ |
| ក្តាម ខ្យង | ៣០០ គក្រ | ២០០០ គក្រ | ២៣០០ គក្រ |
| កង្កែប និងគីង្គក់ | ៥០ គក្រ | ១០០ គក្រ | ១៥០ គក្រ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក. ទស្សនះវិស័យ

សហគមន៍នេសាទ **កំពង់ខ្លាញ់** មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ. គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុប ឬកាត់បន្ថយពីនាទីឡូត៍នេសាទ កន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុងទំនាបលិចទឹកក្នុងរដូវជំនោរឡើងនាទីព្រៃលិចទឹក ។
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែក ផលប្រយោជន៍ធនធានជលផលជូន ប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌ ។
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទ តាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការ ចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

### គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

#### គ.១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ:

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម:

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| បឹងផ្តៅ | ខែ កញ្ញា-ធ្នូ | មងពាក់ | ៧០ ម | ១៤០០ម | |
| បឹងតាប៉ាង | ខែ កញ្ញា-ធ្នូ | មងពាក់ | ៥០ ម | ១៥០០ ម | |

### គ.២ ផែនការកែលំអដែននេសាទ

ផែនការកែលំអដែននេសាទត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

| ឈ្មោះដែននេសាទ | ទំហំ | ទំហំដែលត្រូវកែលំអ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| បឹងអញ្ចាញ | ៥ ហិកតា | ១០០ម × ៥០ម× ១ម | គ្រឿងចក្រ | មិនា ២០០៨ | មិថុនា ២០០៨ | ៣០០០ ដុល្លា |

### គ.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស នឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទ នៃការអភិរក្ស | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| បឹងអញ្ចាញ | ១០០ម×៥០ម×១ម | ធនធានធម្មជាតិ មានជីវចំរុះ | ផ្សព្វផ្សាយ ដាក់លូបោះ បង្គោលខ្សែ លួស ផ្លាក សញ្ញា | ឧសភា ២០០៨ | សីហា ២០០៨ | ២០០០ដុល្លា |

### គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោមៈ

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើ ដែលត្រូវដាំ និងការពារ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១-ដាំព្រៃលិចទឹក មាត់បឹងអញ្ចាញ | ០.៥ ហិកតា | រាំង ត្រស់ | ផ្សាំ បណ្ដុះ បោះបង្គោល | កក្កដា ២០០៨ | សីហា ២០០៨ | ៥០០ដុល្លា |
| ២-ថែរក្សា និង រំលោះព្រៃលិចទឹក | | ទុកកន្លែងត្រីពងកូន | | | | |

### គ.៥- ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្មត្រូវបានរៀបចំឡើងដូចខាងក្រោមៈ

| | | | | | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| ស្រះ | ១០ស្រះ | ប្រា, ឆ្លិន, កាហែ | ៥០០កូន/ស្រះ | ឧសភា ២០០៩ | ឧសភា ២០១០ |

## គ-៦ ផែនការថវិកាទ្រទ្រង់សំរាប់អភិវឌ្ឍសហគមន៍

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ផ្សព្វផ្សាយ | កក្កដា ២០០៩ | តុលា ២០០៩ | ៨០០០០៛ | |
| ភាគទានប្រចាំឆ្នាំ | **ប្រមូល** | កក្កដា ២០០៩ | តុលា ២០០៩ | ៨០០០០៛ | |
| ជំនួយសប្បុរសជន និងអង្គការនានា | គ្មាន | គ្មាន | គ្មាន | គ្មាន | |
| ក្រុមសន្សំប្រាក់ចំនួន ៣ក្រុម | ផ្សព្វផ្សាយផ្តល់ថវិកាបន្ថែមក្នុងក្រុម | មិនា ២០០៨ | មិថុនា ២០០៨ | ១០០០ដុល្លា | |

## គ-៧ ផែនការបង្កើតមុខរបរទ្រទ្រង់ជីវភាពសហគមន៍

| ប្រភេទមុខរបរ | ចំនួន | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|
| ជីកស្រះចិញ្ចឹមត្រី | ១០គ្រួសារ | គ្រឿងចក្រ | ឧសភា ២០០៨ | កក្កដា ២០០៨ | ៥០០០ដុល្លា |
| ចិញ្ចឹមគោ | ៥ គ្រួសារ | - ធ្វើទ្រុង<br>រៀនបច្ចេកទេសពីអ្នកជំនាញ<br>- ដាក់ពូជ | មិថុនា ២០០៩ | កញ្ញា ២០០៩ | ១៥០០ដុល្លា |
| ចិញ្ចឹមមាន់, ជ្រូក | ២០ គ្រួសារ | - ធ្វើទ្រូង<br>រៀនបច្ចេកទេសចិញ្ចឹម<br>- ដាក់ពូជចិញ្ចឹម | មិថុនា ២០០៩ | កញ្ញា ២០០៩ | ២០០០ដុល្លា |

## ឃ. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោម:

- បង្កើតគណ:កម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការ រួមមាន: សមាជិកគណ:កម្មការសហគមន៍នេសាទ ចាស់ទុំ និងសមាជិកសហគមន៍នេសាទដែល មានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែល

ទាក់ទងនឹងបច្ចេកទេសជលផលដូចជា: ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម

- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ កំពង់ខ្លាញ់ រយៈពេល ៣ ឆ្នាំ (២០០៨ ដល់ ២០១០)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | - ផ្សព្វផ្សាយផែនការប្រើប្រាស់ឧបករណ៍នេសាទដល់សមាជិកសហគមន៍ទាំងអស់ និងអ្នកមកពីខាងក្រៅ<br>- ចុះត្រួតពិនិត្យ និងតាមដានជាប្រចាំ | - សមាជិក និងអ្នកមិនមែនជាសមាជិកសហគមន៍ទាំងអស់បានជ្រួតជ្រាបពីផែនការ<br>- ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ថយចុះ នាំឱ្យត្រីមានការកើនឡើង | - ចំណាយលើការផ្សព្វផ្សាយ ១៥០ ដុល្លា<br>ចំណាយលើការចុះ ល្បាតត្រួតពិនិត្យតាមដាន ១៥០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ប្រាក់បដិភាគរបស់សហគមន៍ | ២០០៨ | ២០១០ | |
| ២. ការកែលំអដែននេសាទ | បឹងឆ្អឹងជំរី,ទំហំ ២០០ម x១០០ម<br>បឹងខ្ទ ទំហំ ១៥០ម x១០០ម<br>បោះបង្គោល,ដាក់លូ,ដាក់សំរាស់ | -ជីវភាពកើនឡើង<br>-ជីវភាពសំបូររុងរឿង<br>-រក្សាមេពូជ | ២០០០ ដុល្លា | - អង្គការ<br>- ជំនាញ | មិថុនា ២០០៨ | មករា ២០០៩ | |
| ៣. ការកំណត់ និងរៀបចំតំបន់អភិរក្ស | បឹងខ្ទ ទំហំ ១៥០ម x១០០ម<br>បោះបង្គោល,ដាក់លូ,ដាក់សំរាស់ | -ជីវភាពកើនឡើង<br>-ជីវភាពសំបូររុងរឿង<br>-រក្សាមេពូជ | ២០០០ ដុល្លា | - អង្គការ<br>- ជំនាញ | មិនា ២០០៨ | កក្កដា ២០០៨ | |
| ៤-ផែនការគ្រប់គ្រងព្រៃលិចទឹក | ដាំព្រៃលិចទឹកទំហំ ២ហ.ត រាំង, ត្រស់ | -រក្សាមេពូជត្រី<br>-សំបូរសត្វស្លាប និងធនធានជលផល។<br>- ជីវភាពប្រជាជនកើនឡើង | ៣០០ ដុល្លា | | មិនា ២០០៨ | មិថុនា ២០០៨ | |
| ៥- ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | ចិញ្ចឹមត្រី អណ្តែង ៥ស្រះ ២០ម×១០ម ចំនួន ១០ គក្រ | -ជីវភាពប្រជាជនកើនឡើង<br>-បង្កើនជីវភាពគ្រួសារ | ១២០ ដុល្លា | - សប្បុរសជន<br>- អង្គការ និង ជំនាញ | មិថុនា ២០០៨ | មករា ២០០៩ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៦- ផែនការរកប្រាក់ចំណូលសហគមន៏ | - ប្រមូលប្រាក់សមាជិកភាព និង ភាគទានប្រចាំឆ្នាំ<br>- ស្វែងរកជំនួយបន្ថែមពីអង្គការ និងសប្បុរសជននានា | - សមាជិកស.នទាំងអស់នឹងបង់ប្រាក់តាមការកំនត់ក្នុងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង<br>- អង្គការ និងសប្បុរសជននានា នឹងជួយគាំទ្រតាមរយៈការផ្តល់សំភារៈ និងថវិកាដល់ស.ន | - គ្មានការចំណាយ | - | ២០០៨ | ២០១០ | |
| ៧- ផែនការបង្កើនមុខរបរ ទ្រទ្រង់ជីវភាព | - វិភាគ និងចាត់អាទិភាព ជំរើសមុខរបរចិញ្ចឹមជីវិត<br>- ស្វែងរកអង្គការ ស្ថាប័នគាំទ្រ<br>- រៀបចំសំណើសុំថវិកា | - ជំរើសមុខរបរចិញ្ចឹមជីវិតត្រូវបានកំនត់ និងចាត់អាទិភាព<br>- សំណើសុំថវិកាត្រូវបានរៀបចំ និងទទួលបានការគាំទ្រពីអង្គការនានា | - ចំណាយសរុប ៥០០០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៏ | ២០០៨ | ២០១០ | |

| សកម្មភាព | ឆ្នាំ ២០០៨ | | | | | | | | | | | | ឆ្នាំ ២០០៩ | | | | | | | | | | | | ឆ្នាំ ២០១០ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២. ការកែលំអដែននេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣. ការកំណត់ និង រៀបចំតំបន់អភិរក្ស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្មតាមស្រះ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៦.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧. ផែនការបង្កើនមុខរបរទ្រទ្រង់ជីវភាព | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

ថ្ងៃទី 17 ខែ 10 ឆ្នាំ ២០០8

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

លេខ : 0 2 5 ...

បានឃើញ និងបញ្ជូនមក

លោកនាយអធិការដ្ឋានរដ្ឋបាលជលផល

ថ្ងៃទី 21 ខែ 10 ឆ្នាំ ២០០8

**នាយខណ្ឌរដ្ឋបាលជលផល**

**បានឃើញ**

**មេឃុំ**............

ថ្ងៃទី 23 ខែ 10 ឆ្នាំ ២០០8

លេខ :............

បានឃើញ និងបញ្ជូនមក

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

" ដើម្បីពិនិត្យ និង សម្រេចដោយអនុគ្រោះ "

ថ្ងៃទី 27 ខែ 11 ឆ្នាំ ២០០8

**នាយអធិការដ្ឋានរដ្ឋបាលជលផល**

បានឃើញ និងបញ្ជូនមក

លោកនាយរដ្ឋបាលជលផល

**នាយសង្កាត់រដ្ឋបាលជលផល**

ថ្ងៃទី 17 ខែ 10 ឆ្នាំ ២០០8

លេខ :............

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី...........ខែ............ឆ្នាំ ២០០

**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**